# វិនិយោគលើមាសបៃតង

## ឫស្សីៈសម្ភារៈសំរាប់អនាគត

# ការវិនិយោគលើ ឫស្សី កែច្នៃ នៅកម្ពុជា

ខណៈដែលធនធានឈើហុបធ្លាក់ចុះ និង តម្រូវការធនធានកើនឡើងនៅក្នុងបណ្តាប្រទេសឧស្សាហកម្មទំនើបនានា នៅពេលបច្ចុប្បន្ននេះ វាកាន់តែចាំបាច់បំផុតនៅក្នុងការស្វែងរកឱកាសសម្រាប់សម្ភារៈសំណង់ថ្មីដែលមានលក្ខណៈនិរន្តរភាព។ ដើមឬស្សីគឺមានលក្ខណៈជួយបរិស្ថានខ្លាំង ព្រមទាំងជាធនធានស្រដៀងគ្នានឹងឈើផងដែរ។ ដូច្នេះហើយវាជាសំភារៈមួយប្រភេទដ៏គួរឲ្យទាក់ទាញសម្រាប់ ប្រើជាសម្ភារៈគ្រោងសំណង់ផងដែរ។ ជាមួយមានការស្អិតទំនើបបន្ទះឬស្សីគឺមានលក្ខណៈរឹង និង មានភាពធន់ខ្លាំង និងវាអាចជំនួសមុខងារឈើជាច្រើនផ្សេងៗ។ បន្ទះឬស្សីកែច្នៃ ត្រូវបានគេប្រើប្រាស់បានជាច្រើនប្រភេទ។ វត្ថុប្រើប្រាស់ទាំងនេះរួមមានវត្ថុប្រើប្រាស់នៅក្នុងផ្ទះ ដូចជាគ្រឿងសង្ហារឹមនិងកៅអីខ្ពស់ ព្រមទាំងវត្ថុប្រើប្រាស់ក្នុងផ្ទះជាច្រើនដូចជា ជ្រុញ ធ្មើ វត្ថុតុបតែង និងវត្ថុអនុស្សាវ រីយ៍។ គេក៏អាចប្រើប្រាស់វាសម្រាប់ធ្វើកម្រាលឥដ្ឋ និងបន្ទះមានគុណភាព

|  |  |  |  |
|---|---|---|---|
| គំនូដើមឬស្សីដែលបានកែច្នៃរួច | បន្ទះដើមឬស្សីដែលបានកែច្នៃរួច | ការប្រើប្រាស់: គ្រឿងសង្ហារឹម | ការប្រើប្រាស់:រចនាសម្ព័ន្ធ |

ខ្ពស់ សម្រាប់ពិដាននិង ជញ្ជាំង។ ជាទូទៅឬស្សីកែច្នៃមានពីរពណ៌គឺពណ៌ធម្មជាតិ និងពណ៌ជ័រឈើ(ពណ៌លឿងថ្លា)។ ឬស្សីធម្មជាតិ ដែលគេទុកមិនបានកែច្នៃ គឺបង្ហាញពីលក្ខណៈរបស់ឬស្សីល្អបំផុតដោយសារតែពណ៌ភ្លឺថ្លារបស់វា។ ដែលស្រដៀងគ្នានឹងដើមម៉ាផលដែលមានពណ៌ក្រហម ឬពណ៌មាសនៅរដូវស្លឹកឈើជ្រុះ។ គេអាចធ្វើឲ្យឬស្សីមានពណ៌ជ័រឈើដោយការធ្វើកាបូនកម្ម។

**Contact information:**
ww.aha-kh.com/bamboo
bamboo@aha-kh.com
+855 89 595 668 (English)
+855 12 550 635 (Khmer)

# វិនិយោគលើមាសបៃតង

## ឫស្សីៈសម្ភារៈសំរាប់អនាគត

## ផលិតផល និងទីផ្សារ

ដោយសារឫស្សីកែច្នៃ ផ្តល់ជម្រើសមួយទៀត ជំនួសឲ្យការប្រើប្រាស់ឈើ ទីផ្សារឫស្សីកែច្នៃ នឹងមានការពាក់ព័ន្ធជាមួយការប្រែប្រួលតម្លៃ និងតម្រូវការផលិតផលឈើ។ នៅចំពោះមុខនឹងការកើនឡើងនៃតម្រូវការ ផលិតផលឈើប្រឈមនឹងធនធានឈើធម្មតា មានកំណត់តម្លៃផលិតផលឈើក៏បានកើនឡើងទៀងទាត់នៅក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ។ តម្រូវការឫស្សីកែច្នៃ គឺកំពុងមានការកើនឡើងដែលជាវត្ថុជំនួសឈើ។ លើសពីនេះទៀតមានការប្រែប្រួលទំនោរការទិញរបស់អតិថិជនដែលកំពុងមានការកើនឡើង ដោយគាំទ្រផលិតផលមិនប៉ះពាល់ដល់បរិស្ថាន និងសម្ភារៈដែលអាច កកើតឡើងវិញបាន។ ទីផ្សារប្រើប្រាស់ចម្បងៗសម្រាប់ឫស្សីកែច្នៃគឺមានដូចជាទីផ្សារអឺរ៉ុប និងទីផ្សារ សហរដ្ឋអាមេរិក។ នៅពេលថ្មីៗនេះៗ ការជោគជ័យផ្នែកពាណិជ្ជកម្មផលិតផលឫស្សីកែច្នៃបានកើនឡើងនៅក្នុងបណ្តាប្រទេសអាស៊ីនិងអាស៊ីប៉ូពាំ។

ប្រទេសចិនគឺជាប្រទេសដែលផលិតឫស្សីកែច្នៃច្រើនជាងគេ។ សមត្ថភាពផលិតកម្មរបស់ប្រទេសចិន គឺត្រូវបានគេប៉ាន់ប្រមាណថា នឹងមាន៥០០,០០០ម៉ែត្រគូបនៅក្នុងមួយឆ្នាំៗ។ ប្រហែល៨០% នៃក្តារបន្ទះឫស្សីកែច្នៃត្រូវបានប្រើប្រាស់ជាកម្រាលរនាប និងប្រហែល២០%ទៀតគេយកមកសម្រាប់គ្រឿង សង្ហារឹម និងផលិតផលគ្រោងសំណង់។ ច្រើនជាង៧០%នៃផលិតកម្មរបស់ប្រទេសចិន គឺសម្រាប់ទីផ្សារនាំចេញ និងប្រទេសនាំចូល និងប្រទេសដែលប្រើប្រាស់ដ៏ធំជាងគេ គឺសហរដ្ឋអាមេរិក និងអ៊ឺរ៉ុប។ បរិមាណតិចតួចត្រូវបានផលិតនៅក្នុងប្រទេសវៀតណាម និងប្រទេសនៅអាហ្វ្រិក។ ផលិតកម្មរបស់ប្រទេសវៀតណាម ត្រូវបានគេប៉ាន់ប្រមាណថា មានចំនួន១០,០០០ម៉ែត្រគូបនៅក្នុងមួយឆ្នាំៗ។ ទោះ បីជាវាប្រែប្រួលយ៉ាងខ្លាំងទៅតាមប្រភេទផលិតផលនេះក៏ដោយ ក៏ផលិតកម្មក្តារបន្ទះនិងឈើដុំនៃ ឫស្សីកែច្នៃមិនទាន់សម្រេច គឺមានតម្លៃប្រហែល១០០០ដុល្លារក្នុង១ម៉ែត្រគូបនៅក្នុងរោងចក្រមុនៗ។

## បច្ចេកទេសកែច្នៃ

ស្តង់ដារកែច្នៃផលិតកម្ម សម្រាប់ការកែច្នៃឫស្សី ត្រូវបានបរិយាយនៅក្នុងដ្យាក្រាម។ ដូចដែលបានបង្ហាញនៅក្នុងរូបភាពនេះ ដំបូងដើមរបស់វាត្រូវបានច្រៀកទៅជាបន្ទះទ្រវែង។

១.ការកាត់តម្រឹម → ២. ការបំបែក → ៣.ការតំរៀប → ៤. ការចំហុយ → ៥. ការសង្ងួត
↓
៦. ការរៀបរៀបជាបួនទិស ← ៧. ការដាក់ការ ← ៨.ការគាបជាក្តារបន្ទះ ← ៩.ការកាត់តម្រឹមចុង ← ១០. ការធ្វើជាគ្រឿងសង្ហារឹម

**Contact information:**
ww.aha-kh.com/bamboo
bamboo@aha-kh.com
+855 89 595 668 (English)
+855 12 550 635 (Khmer)

# វិនិយោគលើមាសបៃតង

## ឬស្សីៈសម្ភារៈសំរាប់អនាគត

### ផលិតកម្មកែច្នៃដើមឬស្សី

បន្ទាប់មក បន្ទះឬស្សីទាំងនេះ ត្រូវបានកែច្នៃដើម្បីទប់ស្កាត់ ពីការបំផ្លិចបំផ្លាញរបស់សត្វល្អិត។ បន្ទះដើមឬស្សីទាំងនេះ ត្រូវបានគេសម្ងួតនៅក្នុងឡ និង ត្រូវបានដុសខាត់ឲ្យមានផ្ទៃភ្លឺរលោង សម្រាប់ការបិទបញ្ចូលគ្នា។ បន្ទាប់មកបន្ទះឬស្សី ទាំងនេះត្រូវបានគេដាក់ការបិទភ្ជាប់គ្នានៅតាមជ្រុងដើម្បីបង្កើតក្តារបន្ទះមួយសន្លឹក។ ក្រោយមកទៀតក្តារបន្ទះទាំងនេះ ត្រូវបានដាក់ការហើយបិទបញ្ចូលគ្នា ដើម្បីបង្កើតក្តារបន្ទះឬស្សីមានច្រើនសន្លឹក។បើមិនដូច្នោះទេ ក្តារបន្ទះឬស្សីទាំងនេះត្រូវបានបិទការស្អិតជាប់មុខ ដើម្បីធ្វើជាក្តារបន្ទះឬស្សី សរសៃរបញ្ឈរ។




គោលការណ៍សម្រាប់ការកែច្នៃឬស្សី

បន្ទះឬស្សីដែលមានបិទស្រទាប់បន្ថែមផ្សេងទៀតនេះ ត្រូវបានគេប្រើប្រាស់សម្រាប់មុខកាត់ក្តារបន្ទះ ឬស្សី។ គោលការណ៍នេះ អាចត្រូវបានគេប្រើប្រាស់សម្រាប់ការបង្កើតក្តារបន្ទះ និងដុំឈើឬស្សីសម្រាប់ធ្វើក្តារបន្ទះមុខកាត់នីមួយៗ ដើម្បីបំពេញតាមតម្រូវការប្រើប្រាស់ផ្សេងៗ។

ផលិតកម្មកែច្នៃដើមឬស្សី ត្រូវការបច្ចេកទេសដែលស្រដៀងគ្នា នឹងផលិតផលឈើសំណង់ផ្សេងៗ ហើយបច្ចេកទេសនេះ គឺមានលក្ខណៈពេលពេញនៅក្នុងប្រទេសចិន។ គ្រឿងចក្រសម្រាប់ផលិតកម្មសាមញ្ញក្នុងការផលិតក្តារបន្ទះកែច្នៃ គឺមានតម្លៃពី១០០,០០០ ដុល្លារអាមេរិក ទៅដល់ ៥០០,០០០ដុល្លារអាមេរិក យោងទៅតាមទំហំនៃផលិតកម្មនោះ។ ដើម្បីផលិតគ្រឿងសង្ហារឹមសម្រេច ឬការធ្វើ កម្រាលរនាបគេក៏ត្រូវការឧបករណ៍ និងម៉ាស៊ីនផ្សេងៗផងដែរ។ គ្រឿងឧបករណ៍ដ៏ល្អបំផុតទាំងនេះអាចនាំយកមកពីប្រទេសចិន ប៉ុន្តែវិនិយោគិនអាចពិចារណាពីការនាំគ្រឿងឧបករណ៍ទាំងនេះ ពីភ្នាក់ងារនានានៅក្នុងប្រទេសវៀតណាម។


**Contact information:**
ww.aha-kh.com/bamboo
bamboo@aha-kh.com
+855 89 595 668 (English)
+855 12 550 635 (Khmer)

# វិនិយោគលើមាសបៃតង

## ឫស្សីៈសម្ភារៈសំរាប់អនាគត

## វត្ថុធាតុដើម


ដើមឫស្សីព្រៃ


ដើមឫស្សីស្រុក

ការវាយតម្លៃអំពីធនធានដើមឫស្សី នៅក្នុងស្រុកវ៉ារិន ខេត្តសៀមរាប បង្ហាញថា ប្រភេទឫស្សី និង បរិមាណសមស្របអាចមានច្រើន។ ផែនការគាំទ្រចំពោះការអភិវឌ្ឍន៍ការដាំដុះឫស្សី នឹងធានាដល់ការផ្គត់ផ្គង់មានរយៈពេលយូរ។ ដើមឫស្សីព្រៃ គឺជាវត្ថុធាតុសមស្របដែលមានច្រើនលើសលុប។ ជាឧទាហរណ៍ ផ្ទៃដីចំការឫស្សីថ្មីៗ សម្រាប់អំបូរដើមឫស្សីស្រុកដែលមានស្រាប់និងដើមឫស្សីពីងពង់ អាចត្រូវបានគេលើកយកមកពិចារ ណាដាក់នៅក្នុងផែនការគម្រោងរបស់អ្នកផងដែរ។ រោងចក្រខ្នាតតូចបំផុតមួយ នឹងអាចផលិតក្តារ បន្ទះឈើឫស្សីកែច្នៃ ពី៤០០ ទៅដល់ ៦០០ ម៉ែត្រគូប នៅក្នុងមួយឆ្នាំៗ ដោយប្រើប្រាស់វត្ថុធាតុដើម ឫស្សីចំនួន២៤០០តោនទៅដល់៣៦០០តោន។

## ផ្នែកហិរញ្ញវត្ថុ

តាមការអង្កេតរោងចក្រផលិតផ្សេងៗនៅក្នុងប្រទេសចិន និងវៀតណាមការវិនិយោគលើឫស្សីកែច្នៃ បង្ហាញអំពីចំណូលហិរញ្ញវត្ថុគួរឲ្យទាក់ទាញ។ រយៈពេលនៃផលចំណេញ ត្រូវបានគេព្យាករណ៍សម្រាប់រយៈពេលបីឆ្នាំ។ លើសពីនេះទៀត អាជីវកម្មនេះ អាចរកប្រាក់ចំណូលបន្ថែមលើផលិតកម្មក្តារបន្ទះ និង ឈើដុំឫស្សីដោយបញ្ចូលទាំងគ្រឿងសង្ហារឹម ឬប្រភេទផលិតផលសម្រេចផ្សេងៗទៀត ទៅក្នុងគំរូអាជីវកម្មនេះ។

**Contact information:**
ww.aha-kh.com/bamboo
bamboo@aha-kh.com
+855 89 595 668 (English)
+855 12 550 635 (Khmer)